# ភាពប្រែប្រួលនៃចរិតលក្ខណៈភេទ ក្នុងទារក និងកុមារ

## ព័ត៌មានសម្រាប់គ្រួសារ

អ្នកបានទទួលសន្លឹកព័ត៌មាននេះ ដោយសារតែទារក ឬកូនរបស់អ្នកត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានភាពប្រែប្រួលនៃចរិតលក្ខណៈភេទ។ នេះមានន័យថាកូនរបស់អ្នកកើតមកមានចរិតលក្ខណៈភេទតាមធម្មជាតិ ដែលមិនសមស្របនឹងនិយមន័យធម្មតាសម្រាប់ដងខ្លួនមនុស្សប្រុស ឬមនុស្សស្រី។

ជួនកាលភាពខុសគ្នាទាំងនេះត្រូវបានគេហៅថា ‘ភាពប្រែប្រួលនៃអន្តរភេទ’, ‘ភាពខុសគ្នានៃការបង្កបង្កើតភេទ' ឬ ‘រោគទាក់ទិននឹងការលូតលាស់នៃប្រដាប់បន្តពូជ'។ មនុស្សផ្សេងៗគ្នា ចូលចិត្តពាក្យខុសៗគ្នា។ សម្រាប់សន្លឹកព័ត៌មាននេះ យើងនឹងប្រើពាក្យ ‘ភាពប្រែប្រួលនៃអន្តរភេទ’។

មានភាពប្រែប្រួលនៃអន្តរភេទចំនួន៣០ ដែលអាចប៉ះពាល់ដល់មនុស្សតាមវិធីផ្សេងៗគ្នា។ ភាពប្រែប្រួលនៃអន្តរភេទ អាចបណ្តាលមកពីភាពខុសគ្នានៃក្រូម៉ូសូម អ័រម៉ូន និង / ឬភាពខុសគ្នាខាងកាយវិភាគ។ ទាំងនេះអាចរួមបញ្ចូលការរួមផ្សំគ្នានៃក្រូម៉ូសូមភេទ X និង Y, កម្រិត ឬភាពប្រែប្រួលខុសគ្នាចំពោះអ័រម៉ូនដែលជាទូទៅទាក់ទិនជាមួយភេទមួយ ឬភេទផ្សេងទៀត និងប្រដាប់ភេទ ដែលមើលទៅខុសពីធម្មតាបន្តិច។

ភាពប្រែប្រួលមួយចំនួននៅក្នុងភាពប្រែប្រួលនៃចរិតលក្ខណៈភេទ អាចរកឃើញមុនពេលទារកកើតមក នៅពេលទារកកើតមក ឬក្នុងអំឡុងកុមារភាព។ ខ្លះលេចឡើងនៅពេលពេញវ័យ ជាពិសេសចំពោះអ្នកដែលទាក់ទិនភាពខុសគ្នាក្នុងមុខងារបន្តពូជ។ ភាពប្រែប្រួលផ្សេងទៀត អាចមិនត្រូវបានគេរកឃើញក្នុងអំឡុងពេលនៃជីវិតរស់នៅរបស់បុគ្គលណាម្នាក់ឡើយ។

មនុស្សមួយចំនួនដែលមានភាពប្រែប្រួលនៃអន្តរភេទ មិនបង្កើតភាពប្រែប្រួលនៃចរិតលក្ខណៈភេទជាទូទៅនៃភេទមួយ ឬភេទផ្សេងទៀតឡើយ ហើយខ្លះទៀតបញ្ចូលគ្នានូវលក្ខណៈពិសេសនៃភេទទាំងពីរ។ យ៉ាងណាក៏ដោយ កូនរបស់អ្នកនឹងទៅជា (ឬត្រូវបាន) ចម្រើនធំឡើងទៅជាក្មេងប្រុស ឬក្មេងស្រី។

ចំពោះមនុស្សភាគច្រើនដែលមានភាពប្រែប្រួលនៃអន្តរភេទ ការប្រែប្រួលរបស់ពួកគេមិនអាចមើលឃើញ ឬកត់សម្គាល់ឃើញដោយអ្នកដទៃឡើយក្នុងការប្រាស្រ័យទាក់ទងខាងសង្គមប្រចាំថ្ងៃ។

ភាពប្រែប្រួលនៃអន្តរភេទរបស់កូនអ្នក គឺខុសគ្នាពីអត្តសញ្ញាណយេនឌ័ររបស់ពួកគេ (អារម្មណ៍ខាងក្នុងរបស់ពួកគេថាជាមនុស្សប្រុស ឬមនុស្សស្រី) និងការនិយមផ្លូវភេទរបស់ពួកគេ (មនុស្សដែលពួកគេនឹងត្រូវបានទាក់ទាញចិត្ត)។ មនុស្សភាគច្រើនដែលមានភាពប្រែប្រួលនៃអន្តរភេទ បានកំណត់អត្តសញ្ញាណថាជាក្មេងប្រុស ឬក្មេងស្រី និងមនុស្សដែលស្រឡាញ់មនុស្សមានភេទផ្ទុយគ្នា។ លក្ខណៈទាំងនេះមិនអាចទស្សន៍ទាយជាមុនបានទេ សម្រាប់នរណាម្នាក់នៅក្នុងសង្គម រួមមានមនុស្សដែលមានភាពប្រែប្រួលនៃអន្តរភេទ ហើយមានតែកូនរបស់អ្នកប៉ុណ្ណោះដែលអាចដឹងអំពីការនិយមផ្លូវភេទ និងអត្តសញ្ញាណរបស់ពួកគេ។

## តើភាពប្រែប្រួលនៃអន្តរភេទកើតមានជាទូទៅយ៉ាងណាដែរ?

ព័ត៌មានដែលអាចជឿទុកចិត្តបានអំពីចំនួនមនុស្សដែលមានភាពប្រែប្រួលនៃអន្តរភេទ គឺជាការលំបាកក្នុងការទទួលបានដោយព្រោះហេតុផលជាច្រើន រួមមានការប្រែប្រួលជាច្រើនដែលគេមិនរកឃើញពេញទូទាំងជីវិតរស់នៅរបស់បុគ្គលណាម្នាក់។

ភាពប្រែប្រួលនៃអន្តរភេទ គឺជារឿងធម្មតាដែលមនុស្សជាច្រើនប្រហែលជាយល់ឃើញថា ប្រហែលជាមានស្មើនឹងចំនួនមនុស្សដែលមានសក់ក្រហម។ តាមការប៉ាន់ប្រមាណវាត្រូវបានគេប៉ាន់ស្មានថារវាងទារក១ ទៅ២ភាគរយនៃទារកដែលកើតមក មានទម្រង់នៃការប្រែប្រួលមួយចំនួននៅក្នុងភាពប្រែប្រួលនៃចរិតលក្ខណៈភេទ។ មួយចំនួននៃការប្រែប្រួលទាំងនេះ រួមមានការប្រែប្រួលតិចតួចនៃការលូតលាស់នៃប្រដាប់បន្តពូជ  ដែលជាលទ្ធផលមិនត្រូវការបន្ត ឬប្រាស្រ័យទាក់ទងយូរអង្វែងជាមួយប្រព័ន្ធសុខភាពឡើយ។

ភាពប្រែប្រួលនៃក្រូម៉ូសូមលាយចម្រុះគ្នា ដូចជាសហរោគសញ្ញា Klinefelter, សហរោគសញ្ញា Triple X និងសហរោគសញ្ញា Turner គឺជារោគវិនិច្ឆ័យទូទៅបំផុត។ ភាពប្រែប្រួលនៃអន្តរភេទ ទាក់ទងនឹងប្រដាប់ភេទដែលមើលទៅខុសគ្នា (ខុសពីធម្មតា) គឺមិនសូវឃើញញឹកញាប់ទេ។

## តើភាពប្រែប្រួលនៃអន្តរភេទត្រូវការការព្យាបាលឬទេ ?

មនុស្សភាគច្រើនដែលមានភាពប្រែប្រួលនៃអន្តរភេទ គឺមានសុខភាពល្អ និងនាំមកនូវជីវិតសប្បាយរីករាយប្រកបដោយជោគជ័យ។ មានបញ្ហាសុខភាពរាងកាយមួយចំនួន និងបញ្ហាការយល់ដឹង និងការអភិវឌ្ឍទាក់ទិនជាមួយនឹងភាពប្រែប្រួលនៃអន្តរភេទជាក់លាក់។ វាជាការសំខាន់ណាស់ក្នុងការទទួលបានព័ត៌មានត្រឹមត្រូវដើម្បីយល់ច្បាស់ពីបញ្ហា និងហានិភ័យទាក់ទិននឹងភាពប្រែប្រួលនៃអន្តរភេទជាក់លាក់របស់កូនអ្នក ដើម្បីធ្វើការសម្រេចចិត្តដោយត្រឹមត្រូវអំពីការថែទាំ និងការព្យាបាលដ៏ល្អបំផុតរបស់ពួកគេ។

ប្រសិនបើអ្នកកំពុងទទួលបានការធ្វើរោគវិនិច្ឆ័យនៃភាពប្រែប្រួលនៃអន្តរភេទសម្រាប់ទារកទើបនឹងកើតរបស់អ្នក ការសម្រេចចិត្តដើម្បីចិញ្ចឹមកូនរបស់អ្នកជាក្មេងស្រី ឬក្មេងប្រុសគឺជាការសម្រេចចិត្តដ៏សំខាន់។ ក្រុមអ្នកជំនាញផ្នែកសុខភាពរបស់អ្នកអាចជួយអ្នកក្នុងការសម្រេចចិត្តនេះ។ ប៉ុន្តែវាក៏ជាការសម្រេចចិត្តសម្រាប់ពេលឥឡូវនេះប៉ុណ្ណោះ។ មានតែកូនរបស់អ្នកប៉ុណ្ណោះដែលដឹងថា ពួកគេមានអត្តសញ្ញាណជាមនុស្សប្រុស ឬមនុស្សស្រី។

ប្រសិនបើអ្នកកំពុងទទួលការធ្វើរោគវិនិច្ឆ័យអំពីកូនវ័យចំណាស់ដែលមានភាពប្រែប្រួលនៃអន្តរភេទ នោះកូនរបស់អ្នកនឹងបានចម្រើនធំឡើងក្នុងភាពជាក្មេងប្រុស ឬក្មេងស្រីរួចទៅហើយ។ ក្នុងករណីខ្លះ ការប្រែប្រួលរបស់ពួកគេអាចមានឥទ្ធិពលលើការរីកចម្រើនក្នុងអំឡុងពេលពេញវ័យ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ យើងសូមលើកទឹកចិត្តឱ្យអ្នកពិភាក្សាពីបញ្ហាទាំងនេះដោយបើកចំហជាមួយកូនរបស់អ្នក។ ការគាំទ្រ និងការបញ្ជាក់ពីជម្រើសរបស់ពួកគេគឺសំខាន់ណាស់សម្រាប់សុខុមាលភាពរបស់ពួកគេ។

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលវេលារបស់អ្នក នៅពេលធ្វើការសម្រេចចិត្តព្យាបាលក្នុងនាមកូនរបស់អ្នក។ ការព្យាបាលមួយចំនួនមិនអាចត្រឡប់វិញបានទេ ហើយការព្យាបាលជាច្រើនអាចពន្យារពេលបានរហូតដល់ទារក ឬកូនរបស់អ្នកមានអាយុគ្រប់គ្រាន់ដើម្បីសម្រេចចិត្តដោយខ្លួនឯង។

ចំណាយពេលរបស់អ្នក ស្វែងរកដំបូន្មាន ហើយជៀសវាងការមានអារម្មណ៍ក្រោមសម្ពាធដើម្បីធ្វើការសម្រេចចិត្ត មុនពេលអ្នក ឬកូនរបស់អ្នកត្រៀមខ្លួនរួចរាល់។ វាអាចជាការប្រសើរដើម្បីពន្យារការព្យាបាល រហូតដល់កូនរបស់អ្នកមានអាយុគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងការសម្រេចចិត្តដោយខ្លួនឯង។

**រូបភាព១៖ ការណែនាំមួយជំហានម្តងៗសម្រាប់មាតាបិតា**

ទទួលបានការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ។ ទទួលបានព័ត៌មានពេញលេញអំពីភាពមិនដូចគ្នារបស់កូនអ្នក

↓

ចិញ្ចឹមកូនរបស់អ្នកជាក្មេងប្រុស ឬក្មេងស្រី - ដំបូន្មានពីអ្នកជំនាញខាងវេជ្ជសាស្ត្រ និងមិត្តភក្តិអាចជួយអ្នកក្នុងការសម្រេចចិត្ត

↓

ទទួលបានការប្រឹក្សាយោបល់សមស្រប ក្រុមមិត្តភក្តិ និងការគាំទ្រផ្សេងៗទៀតដែលអាចជួយអ្នកឱ្យបានយល់ដឹង និងដោះស្រាយជាមួយភាពមិនដូចគ្នាជាក់លាក់របស់កូនអ្នក

↓

ប្រសិនបើត្រូវបានណែនាំឱ្យធ្វើការវះកាត់ ចូរពិគ្រោះអំពីជម្រើសនៃការព្យាបាលទាំងអស់ ហើយស្វែងរកមតិយោបល់ទីពីរ។ កុំប្រញាប់ធ្វើការសម្រេចចិត្តណាមួយ ពិចារណាអំពីជម្រើសនៃការមិនព្យាបាលវិញ

↓

ប្រាប់កូនអំពីរាងកាយរបស់ពួកគេទៅតាមដំណាក់កាល នៅពេលពួកគេមានវ័យធំឡើង និងអាចដឹងយល់ពីគំនិតមួយចំនួន

↓

ធានាថាកូនរបស់អ្នកត្រូវបានផ្តល់ព័ត៌មានយ៉ាងពេញលេញអំពីភាពប្រែប្រួលរបស់ពួកគេ នៅពេលពួកគេចូលដល់វ័យជំទង់ ហើយជួយគាំទ្រពួកគេឱ្យធ្វើការសម្រេចចិត្តអំពីសេចក្តីត្រូវការការព្យាបាល ការថែទាំ និងការគាំទ្ររបស់ពួកគេ។

**ចំណាំ៖** សម្របសម្រួលពី *ការណែនាំសម្រាប់មាតាបិតាកុមារដែលមានប្រដាប់ភេទប្រុសផងស្រីផង ឆ្នាំ២០១៦* Androgen Insensitivity Syndrome Support Group Australia Inc ក្រុមផ្តត់ផ្គង់ ព័ត៌មាន និងការគាំទ្រសម្រាប់មនុស្សអន្តរភេទ និងក្រុមគ្រួសាររបស់ពួកគេ <http://aissga.org.au/fact_sheets.htm>។

## តើខ្ញុំគួរប្រាប់ពួកមនុស្សឯទៀតពីអ្វីខ្លះ?

ការទទួលបានការធ្វើរោគវិនិច្ឆ័យនៃភាពប្រែប្រួលនៃអន្តរភេទ អាចជាពេលវេលាដ៏តានតឹងមួយសម្រាប់អ្នក និងកូនរបស់អ្នក។ ការទទួលបានព័ត៌មានត្រឹមត្រូវ និងការគាំទ្រដែលប្រកបដោយគុណភាពពីប្រភពដែលជឿទុកចិត្ត នឹងមានសារៈសំខាន់នៅពេលនេះ។

អ្នកប្រហែលជាមានអារម្មណ៍ច្របូកច្របល់អំពីការនិយាយជាមួយក្រុមគ្រួសារ និងមិត្តភក្តិ អំពីភាពប្រែប្រួលនៃអន្តរភេទនៃកូនរបស់អ្នក ឬមិនច្បាស់លាស់អំពីរបៀបឆ្លើយសំណួរណាមួយដែលពួកគេអាចមាន។ វាអាចត្រូវការពេលវេលាដើម្បីថ្លឹងថ្លែងបំណងប្រាថ្នារបស់អ្នក ដើម្បីការពារកូនរបស់អ្នក និងភាពឯកជនរបស់ពួកគេ ដោយមានការបើកចំហអំពីបទពិសោធន៍របស់ពួកគេដែលជៀសវាងភាពសម្ងាត់ ឬការអាម៉ាស់។ វាជាការសំខាន់ណាស់ក្នុងការធ្វើអ្វីៗដែលល្អបំផុតសម្រាប់អ្នក កូនរបស់អ្នក និងគ្រួសាររបស់អ្នក។

នៅពេលកូនរបស់អ្នកកាន់តែមានវ័យធំ វានឹងមានសារៈសំខាន់ក្នុងការផ្តល់នូវការពន្យល់ដែលសមស្របតាមអាយុអំពីការប្រែប្រួលរបស់ពួកគេ ការព្យាបាលផ្នែកវេជ្ជសាស្ត្រដែលពួកគេកំពុងជួបប្រទះ និងជម្រើសមួយចំនួនដែលមានសម្រាប់ពួកគេ និងការជ្រើសរើសរបស់ពួកគេ។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅកន្លែងណា?

អ្នកនឹងត្រូវបានគេផ្តត់ផ្គត់ដោយការបញ្ជូនទៅកាន់មន្ទីរពេទ្យ Royal Children's Hospital (មន្ទីរពេទ្យកុមារ) ឬមន្ទីរពេទ្យ Monash Children’s Hospital (មន្ទីរពេទ្យ កុមារម៉ូណាស្ហ) ដែលអ្នកនឹងទទួលបានការគាំទ្រពីក្រុមអ្នកជំនាញវិជ្ជាជីវៈផ្នែកសុខភាព។ រួមជាមួយការគាំទ្រពីក្រុមគ្រួសារ និងមិត្តភក្តិដែរនោះ អ្នកក៏អាចស្វែងរកការគាំទ្រពីក្រុមគាំទ្រអ្នកឯកទេស ដែលបង្កើតឡើងដោយអ្នកដទៃដែលមានបទពិសោធន៍ដូចនឹងអ្នកដែរ។

សម្រាប់ព័ត៌មានទំនាក់ទំនងបន្ថែម៖

- អ្នកសម្របសម្រួលគ្លីនិកនៃមន្ទីរពេទ្យកុមារ៖ (03) 9345 7033 ឬ (03) 9345 5522 (ប្រតិបត្តិកទូរស័ព្ទ)
- មន្ទីរព្យាបាលជំងឺក្រពះនៃមន្ទីរពេទ្យម៉ូណាស្ហ៖ (03) 9594 4723
- AISSGA (Androgen Insensitivity Syndrome Support Group Australia) <http://www.aissga.org.au>
- Australian X and Y Spectrum Support (AXYS) <https://axys.org.au>
- CAH Support Group Australia <http://www.cah.org.au>
- Genetic Support Network Victoria <https://www.gsnv.org.au>
- Intersex Human Rights Australia <https://ihra.org.au>
- Turner Syndrome Association of Australia <https://www.turnersyndrome.org.au>.

---

ដើម្បីទទួលបានការបោះពុម្ពផ្សាយនេះក្នុងទម្រង់ដែលអាចចូលប្រើបាន អ៊ីម៉េល DHHS diversity <diversity@dhhs.vic.gov.au>

ត្រូវបានអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ ក្រសួងសុខភាព និងសេវាកម្មមនុស្ស ខែមីនា ឆ្នាំ២០១៩។

© State of Victoria, Department of Health and Human Services, March 2019.
ISBN 978-1-76069-686-3 (pdf/អនឡាញ/MS word) ISBN 978-1-76069-753-2 (បោះពុម្ព)

អាចរកបាននៅ Health of people with intersex variations <https://www2.health.vic.gov.au/about/populations/lgbti-health/health-of-people-with-intersex-variations>

បោះពុម្ពដោយ TDC3, Richmond (1810017 banner)